ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៨៦៣......សហវ.ប្រក

អង្គភាពប្រឆាំងអំពើពុករលួយ
ចូល
លេខ ១៣១១.១៦........
ថ្ងៃទី២៧.០៧.១៦ ម៉ោង០៩:១០

# ប្រកាសរួម
## ស្តីពី
## ការលក់លេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តធុនស្រាល

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសាធារណការ និងដឹកជញ្ជូន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រិសារពើពន្ធ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- យោងតាមការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

អនុញ្ញាតឱ្យមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត អនុវត្តប្រមូលចំណូលពីការលក់លេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តធុនស្រាល ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២.-**

សម្រាប់ប្រើប្រាស់ក្នុងប្រកាសរួមនេះ វាក្យស័ព្ទខាងក្រោមមានន័យដូចតទៅ ÷

លេខចុះបញ្ជីរថយន្ត ឬ លេខចុះបញ្ជី សំដៅត្រឹមលេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តធុនស្រាល សម្រាប់ការចេញផ្លាកលេខ និងចេញប័ណ្ណសម្គាល់ ដើម្បីកំណត់អត្តសញ្ញាណរថយន្តនីមួយៗ តែប៉ុណ្ណោះ។

ស៊េរីលេខចុះបញ្ជី សំដៅដល់សំណុំលេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តធុនស្រាល ដែលស្ថិតនៅក្នុងលំដាប់អក្សរឡាតាំងនីមួយៗ ដែលបានកំណត់ទៅតាមលំដាប់លំដោយអក្សរ។

លេខពិសេស សំដៅដល់លេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តធុនស្រាលមួយចំនួន ដែលមានលក្ខណៈពិសេស ត្រូវបានកំណត់ស្របតាមការពេញនិយមនាពេលបច្ចុប្បន្នភាពរបស់អតិថិជនមួយចំនួន និងត្រូវបានជ្រើសរើសចេញពីស៊េរីលេខចុះបញ្ជីនីមួយៗ។

លេខធម្មតា សំដៅដល់លេខចុះបញ្ជីរថយន្តគ្រួសារ និងរថយន្តដឹកទំនិញស្រាលមួយចំនួន ដែលស្ថិតនៅក្នុងស៊េរីលេខចុះបញ្ជីនីមួយៗ មិនរាប់បញ្ចូលលេខពិសេស។

លេខចុះបញ្ជីផ្លោះស៊េរី សំដៅដល់លេខពិសេស និងលេខធម្មតា ដែលស្ថិតនៅក្នុងស៊េរីបន្តបន្ទាប់នៃស៊េរីលេខចុះបញ្ជីបច្ចុប្បន្នភាព។ ស៊េរីលេខចុះបញ្ជីបច្ចុប្បន្នភាព ត្រូវបានកំណត់ដោយអគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការ និងដឹកជញ្ជូន។

បំពាក់ផ្លាកលេខ សំដៅដល់ការចាប់ផ្លាកលេខភ្ជាប់ទៅនឹងរថយន្ត ដោយមានប្រើខ្មៅ និងសៀល នៅពេលម្ចាស់រថយន្តបានបំពេញបែបបទត្រឹមត្រូវ និងស្នើសុំចុះបញ្ជីរថយន្ត។

ប្រការ៣ ._

ការលក់លេខចុះបញ្ជីរថយន្ត ត្រូវបានបែងចែកជាបីតំបន់ ដូចខាងក្រោម ៖

- តំបន់ ១ : លេខរថយន្ត សម្រាប់ចុះបញ្ជីនៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ។
- តំបន់ ២ : លេខរថយន្ត សម្រាប់ចុះបញ្ជីនៅមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកណ្តាល, ខេត្តកំពង់ចាម, ខេត្តបាត់ដំបង, ខេត្តសៀមរាប, ខេត្តព្រះសីហនុ និងខេត្តត្បូងឃ្មុំ។
- តំបន់ ៣ : លេខរថយន្ត សម្រាប់ចុះបញ្ជីនៅមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រៃវែង, ខេត្តកំពង់ធំ, ខេត្តតាកែវ, ខេត្តស្វាយរៀង, ខេត្តពោធិ៍សាត់, ខេត្តកំពង់ឆ្នាំង, ខេត្តកំពង់ស្ពឺ, ខេត្តកំពត, ខេត្តកោះកុង, ខេត្តព្រះវិហារ, ខេត្តក្រចេះ, ខេត្តរតនគិរី, ខេត្តមណ្ឌលគិរី, ខេត្តបន្ទាយមានជ័យ, ខេត្តស្ទឹងត្រែង, ខេត្តឧត្តរមានជ័យ, ខេត្តប៉ៃលិន និងខេត្តកែប។

ប្រការ៤ ._

លេខចុះបញ្ជីរថយន្ត ត្រូវបានកំណត់តម្លៃលក់ ដោយបែងចែកទៅតាមប្រភេទលេខពិសេស និងលេខចុះបញ្ជីផ្លោះស៊េរី ព្រមទាំងកំណត់តម្លៃទៅតាមតំបន់នីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ។

តម្លៃលក់លេខចុះបញ្ជីរថយន្តដែលចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ មិនទាន់គិតបញ្ចូលកម្រៃសេវាសាធារណៈដែលបានកំណត់ដោយប្រកាសរួមលេខ ០១០ សហវ.ប្រក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

ប្រការ៥ ._

ការលក់ ការទិញ និងការចុះបញ្ជីរថយន្ត សម្រាប់ប្រភេទលេខពិសេស និងលេខចុះបញ្ជីផ្លោះស៊េរី ត្រូវគោរពតាមលក្ខខណ្ឌចាំបាច់មួយចំនួន ដូចខាងក្រោម ៖

១- ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការ ដើម្បីទទួលបម្រើសេវាលក់លេខពិសេស និងលេខចុះបញ្ជីផ្ដោះស៊េរី ជូនអតិថិជនឱ្យបានទាន់ពេលវេលា។ ការលក់លេខពិសេស និងលេខចុះបញ្ជីផ្ដោះស៊េរី អាចធ្វើឡើងនៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ឬ នៅទីតាំងកំណត់ជាក់លាក់ណាមួយ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

២- ការលក់ និងការទិញលេខពិសេស និងលេខចុះបញ្ជីផ្ដោះស៊េរី រវាងមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ឬ កន្លែងផ្ដល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងអតិថិជន មានព្រំដែនកំណត់ត្រឹមផ្ទៃក្នុងរាជធានី ខេត្តនីមួយៗ ដែលម្ចាស់រថយន្តមានអាសយដ្ឋានអចិន្ត្រៃយ៍ និងតម្រូវឱ្យចុះបញ្ជីរថយន្តនៅក្នុងរាជធានី ខេត្តនោះ តែប៉ុណ្ណោះ។

៣- រាល់ការទិញលេខពិសេស និងលេខចុះបញ្ជីផ្ដោះស៊េរី តម្រូវឱ្យអតិថិជនបង្ហាញអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរច្បាប់ដើម ឬ ឯកសារដែលមានតម្លៃស្មើ ដើម្បីថតចម្លងទុកជាឯកសារ, លេខទូរស័ព្ទរបស់សាមីខ្លួន និងបង់ប្រាក់ថ្លៃទិញលេខចុះបញ្ជីរថយន្តទៅតាមតម្លៃដែលបានកំណត់ ដែលមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ។

៤- អតិថិជនដែលបានទិញលេខពិសេស និងលេខចុះបញ្ជីផ្ដោះស៊េរី ត្រូវបំពេញបែបបទស្នើសុំចុះបញ្ជីរថយន្តឱ្យបានរួសរាន់ក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលអតិថិជនបានបង់ប្រាក់ទិញលេខចុះបញ្ជីនោះ។ ក្នុងករណីដែលអតិថិជនមានការយឺតយ៉ាវ ឬ ខកខានមិនបានចុះបញ្ជីក្នុងរយៈពេលកំណត់ ៣០(សាមសិប)ថ្ងៃ នឹងត្រូវទទួលរងការរឹបអូសលេខចុះបញ្ជីដែលបានទិញនោះ ដោយពុំមានការផ្ដល់សំណងអ្វីឡើយ ហើយក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវប្រកាសដាក់លក់លេខទាំងនោះសាជាថ្មីទៀត។

៥- ការធ្វើប័ណ្ណសម្គាល់ជូនម្ចាស់រថយន្ត ត្រូវតែផ្ទៀងផ្ទាត់ព័ត៌មានអំពីឈ្មោះ, ភេទ, អាយុ និងអាសយដ្ឋានអចិន្ត្រៃយ៍ ដែលចុះក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់សាមីអតិថិជន ដែលបានរក្សាទុកនៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ឬ កន្លែងផ្ដល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន នាពេលលក់ទិញលេខចុះបញ្ជីរថយន្ត។

៦- ការបំពាក់ផ្លាកលេខ ត្រូវធ្វើឡើងមិនឱ្យលើសពីរយៈពេលមួយម៉ោង បន្ទាប់ពីម្ចាស់រថយន្តបានបំពេញបែបបទស្នើសុំចុះបញ្ជីបានត្រឹមត្រូវ និងផ្ដល់ឯកសារភ្ជាប់គ្រប់គ្រាន់។

៧- ការផ្ដល់ប័ណ្ណសម្គាល់រថយន្ត ត្រូវធ្វើឡើងស្របតាមរយៈពេលផ្ដល់សេវា ដែលកំណត់ដោយប្រកាសរួមលេខ ០១០ សហវ.ប្រក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

ប្រការ៦ .-

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ឬ កន្លែងផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវផ្សព្វផ្សាយជាសាធារណៈឱ្យបានទូលំទូលាយនូវប្រកាសរួម និងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ។ ជាពិសេស ត្រូវផ្សព្វផ្សាយអំពីស្ថានភាពបច្ចុប្បន្នភាពនៃលេខចុះបញ្ជីទាំងអស់នៃស៊េរីលេខចុះបញ្ជីនីមួយៗដែលត្រូវដាក់លក់, លេខពិសេស និងលេខចុះបញ្ជីផ្លោះស៊េរី ដែលអតិថិជនបានទិញរួច ដោយមានបញ្ជាក់អំពីឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់សាមីជន ព្រមទាំងលេខពិសេស និងលេខចុះបញ្ជីផ្លោះស៊េរី ដែលនៅសល់ទំនេរ សម្រាប់ការលក់បន្ត ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជន(ម្ចាស់រថយន្ត) សម្រាប់ការពិនិត្យ និងការសម្រេចចិត្តទិញយកលេខចុះបញ្ជីប្រភេទណាមួយ ដែលសាមីខ្លួនពេញចិត្ត។

បែបបទ នីតិវិធី និងលក្ខខណ្ឌ សម្រាប់ការលក់ និងការទិញលេខពិសេស និងលេខចុះបញ្ជីផ្លោះស៊េរី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

ប្រការ៧ .-

រាល់ការទិញលេខពិសេស និងលេខចុះបញ្ជីផ្លោះស៊េរី ដែលមានចែងក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ តម្រូវឱ្យអតិថិជនបង់ប្រាក់នៅធនាគារដៃគូណាមួយ តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ប៉ុន្តែក្នុងករណីដែលការបង់ប្រាក់នៅធនាគារដៃគូមិនទាន់អាចប្រព្រឹត្តទៅបាន អតិថិជនត្រូវបង់ប្រាក់នៅមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្តសាមី ឬ កន្លែងផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

រាល់ការទទួលប្រាក់ចំណូលជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ លើការលក់លេខពិសេស និងលេខចុះបញ្ជីផ្លោះស៊េរី មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ឬ កន្លែងផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ៨ .-

អនុញ្ញាតឱ្យបង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីគ្រប់គ្រងការលក់លេខចុះបញ្ជីរថយន្ត ដែលកំណត់ដោយប្រកាសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។ គណៈកម្មការអន្តរក្រសួងនេះ ដឹកនាំដោយតំណាងក្រសួងសាធារណការ និងដឹកជញ្ជូន ដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, តំណាងអង្គភាពប្រឆាំងអំពើពុករលួយ, តំណាងសាលារាជធានីភ្នំពេញ និងតំណាងអគ្គនាយកដ្ឋានដឹកជញ្ជូន។

ប្រការ៩ .-

ប្រាក់ចំណូលទាំងអស់ដែលបានមកពីការលក់លេខចុះបញ្ជីរថយន្តនៅតាមមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ត្រូវកំណត់ឱ្យបង់ចូលគណនីរួមមួយ ដែលគ្រប់គ្រងដោយអគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន។ ការបើកគណនីនៅធនាគារពាណិជ្ជណាមួយ សម្រាប់ការទទួលប្រាក់ចំណូលនេះ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការចាត់ចែងប្រាក់ចំណូលដែលបានមកពីការលក់លេខចុះបញ្ជីរថយន្ត ត្រូវអនុវត្តតាមការសម្រេចរួមរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ១០ .-

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ឬ កន្លែងផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវបើកទូលាយដោយមានដាក់លេខទូរស័ព្ទ សារអេឡិចត្រូនិក បណ្តាញសង្គម ប្រអប់សំបុត្រ និងផ្តល់និកាសឱ្យអតិថិជនអាចធ្វើទំនាក់ទំនង ឬ ប្តឹងទៅអគ្គនាយកដ្ឋានដឹកជញ្ជូន ឬ ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬ ប្តឹងទៅអង្គភាពប្រឆាំងអំពើពុករលួយ ផងដែរ។

ប្រការ១១ .-

មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ឬ កន្លែងផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវធ្វើរបាយការណ៍ស្តីពីការប្រមូលចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើជូនអគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

ប្រការ១២ .-

អគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវបូកសរុបលទ្ធផលប្រចាំខែស្តីពីស្ថានភាពនៃការលក់លេខចុះបញ្ជីរថយន្ត ដែលប្រព្រឹត្តទៅនៅតាមរាជធានី ខេត្ត ដាក់ជូនរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១៥ នៃខែបន្ទាប់។

ប្រការ១៣ .-

ប្រភេទលេខ និងតម្លៃលក់នៃលេខពិសេស និងលេខចុះបញ្ជីផ្លោះសើរ អាចកែប្រែបានអាស្រ័យតាមការចាំបាច់ ដែលកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។



42

ប្រការ១៤ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

ប្រការ១៥ .-

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៦

| | |
|---|---|
| ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន | ស៊ុន ចាន់ថុល |

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់ស៊េរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃស៊េរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្ដោះក្នុងមួយស៊េរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| | - ០០១១, ០០២២, ០០៣៣, ០០៤៤, ០០៥៥ | | | | | | |
| | - ០០៦៦, ០០៧៧, ០០៨៨, ០០៩៩, ១១០០ | | | | | | |
| | - ១១៤៤, ២២០០, ២២៤៤, ៣៣០០, ៣៣៤៤ | | | | | | |
| | - ៤៤០០, ៤៤១១, ៤៤២២, ៤៤៣៣, ៤៤៥៥ | ៨០០ ០០០ | ៤០០ ០០០ | ២០០ ០០០ | ៨០០ ០០០ | ៤០០ ០០០ | ២០០ ០០០ |
| | - ៤៤៦៦, ៤៤៧៧, ៤៤៨៨, ៤៤៩៩, ៥៥០០ | | | | | | |
| | - ៥៥៤៤, ៦៦០០, ៦៦៤៤, ៧៧០០, ៧៧៤៤ | | | | | | |
| | - ៨៨០០, ៨៨៤៤, ៩៩០០, ៩៩៤៤ | | | | | | |
| ៥ | លេខបីខ្ទង់ខាងចុង ជាលេខដូចគ្នា | | | | | | |
| | - ០១១១, ០២២២, ០៣៣៣, ០៥៥៥, ០៦៦៦ | | | | | | |
| | - ០៧៧៧, ០៨៨៨, ០៩៩៩, ១២២២, ១៣៣៣ | | | | | | |
| | - ១៥៥៥, ១៦៦៦, ១៧៧៧, ១៨៨៨, ១៩៩៩ | ៤ ០០០ ០០០ | ២ ០០០ ០០០ | ១ ០០០ ០០០ | ១ ២០០ ០០០ | ៦០០ ០០០ | ៣០០ ០០០ |
| | - ២១១១, ២៣៣៣, ២៥៥៥, ២៦៦៦, ២៧៧៧ | | | | | | |
| | - ២៨៨៨, ២៩៩៩, ៣១១១, ៣២២២, ៣៥៥៥ | | | | | | |



| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់ស៊េរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃស៊េរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្ដោះក្នុងមួយស៊េរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| | - ៣៦៦៦, ៣៧៧៧, ៣៨៨៨, ៣៩៩៩, ៥១១១ | | | | | | |
| | - ៥២២២, ៥៣៣៣, ៥៦៦៦, ៥៧៧៧, ៥៨៨៨ | | | | | | |
| | - ៥៩៩៩, ៦១១១, ៦២២២, ៦៣៣៣, ៦៥៥៥ | | | | | | |
| | - ៦៧៧៧, ៦៨៨៨, ៦៩៩៩, ៧១១១, ៧២២២ | ៤ ០០០ ០០០ | ២ ០០០ ០០០ | ១ ០០០ ០០០ | ១ ២០០ ០០០ | ៦០០ ០០០ | ៣០០ ០០០ |
| | - ៧៣៣៣, ៧៥៥៥, ៧៦៦៦, ៧៨៨៨, ៧៩៩៩ | | | | | | |
| | - ៨១១១, ៨២២២, ៨៣៣៣, ៨៥៥៥, ៨៦៦៦ | | | | | | |
| | - ៨៧៧៧, ៨៩៩៩, ៩១១១, ៩២២២, ៩៣៣៣ | | | | | | |
| | - ៩៥៥៥, ៩៦៦៦, ៩៧៧៧, ៩៨៨៨ | | | | | | |
| | - ០៤៤៤, ១០០០, ១៤៤៤, ២០០០, ២៤៤៤ | | | | | | |
| | - ៣០០០, ៣៤៤៤, ៤០០០, ៤១១១, ៤២២២ | | | | | | |
| | - ៤៣៣៣, ៤៥៥៥, ៤៦៦៦, ៤៧៧៧, ៤៨៨៨ | ៨០០ ០០០ | ៤០០ ០០០ | ២០០ ០០០ | ៨០០ ០០០ | ៤០០ ០០០ | ២០០ ០០០ |
| | - ៤៩៩៩, ៥០០០, ៥៤៤៤, ៦០០០, ៦៤៤៤ | | | | | | |
| | - ៧០០០, ៧៤៤៤, ៨០០០, ៨៤៤៤, ៩០០០ | | | | | | |
| | - ៩៤៤៤ | | | | | | |

| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់សេរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃសេរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្ទេរក្នុងមួយសេរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| ៦ | លេខពីរខ្ទង់ខាងដើម ជាលេខដូចគ្នានឹងលេខពីរខ្ទង់ខាងចុង | | | | | | |
| | - ១២១២, ១៣១៣, ១៤១៤, ១៦១៦, ១៧១៧<br>- ១៨១៨, ១៩១៩, ២១២១, ២៣២៣, ២៤២៤<br>- ២៦២៦, ២៧២៧, ២៨២៨, ២៩២៩, ៣១៣១<br>- ៣២៣២, ៣៤៣៤, ៣៦៣៦, ៣៧៣៧, ៣៨៣៨<br>- ៣៩៣៩, ៤១៤១, ៤២៤២, ៤៣៤៣, ៤៦៤៦<br>- ៤៧៤៧, ៤៨៤៨, ៤៩៤៩, ៦១៦១, ៦២៦២<br>- ៦៣៦៣, ៦៤៦៤, ៦៧៦៧, ៦៨៦៨, ៦៩៦៩<br>- ៧១៧១, ៧២៧២, ៧៣៧៣, ៧៤៧៤, ៧៦៧៦<br>- ៧៨៧៨, ៧៩៧៩, ៨១៨១, ៨២៨២, ៨៣៨៣<br>- ៨៤៨៤, ៨៦៨៦, ៨៧៨៧, ៨៩៨៩, ៩១៩១<br>- ៩២៩២, ៩៣៩៣, ៩៤៩៤, ៩៦៩៦, ៩៧៩៧<br>- ៩៨៩៨ | ៣ ០០០ ០០០ | ១ ៥០០ ០០០ | ៧៥០ ០០០ | ១ ០០០ ០០០ | ៥០០ ០០០ | ២៥០ ០០០ |



| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់សេរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃសេរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្ទេរក្នុងមួយសេរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| | - ០១០១, ០២០២, ០៣០៣, ០៤០៤, ០៥០៥<br>- ០៦០៦, ០៧០៧, ០៨០៨, ០៩០៩, ១០១០<br>- ១៥១៥, ២០២០, ២៥២៥, ៣០៣០, ៣៥៣៥<br>- ៤០៤០, ៥១៥១, ៥២៥២, ៥៣៥៣, ៥៤៥៤<br>- ៥៦៥៦, ៥៧៥៧, ៥៨៥៨, ៥៩៥៩, ៥០៥០<br>- ៤៥៤៥, ៦០៦០, ៦៥៦៥, ៧០៧០, ៧៥៧៥<br>- ៨០៨០, ៨៥៨៥, ៩០៩០, ៩៥៩៥ | ៦០០ ០០០ | ៣០០ ០០០ | ១៥០ ០០០ | ៥០០ ០០០ | ៤០០ ០០០ | ២០០ ០០០ |
| ៧ | លេខបីខ្ទង់ខាងដើម ជាលេខដូចគ្នា | | | | | | |
| | - ០០០១, ០០០៧, ០០០៩, ១១១២, ១១១៦<br>- ១១១៧, ១១១៨, ១១១៩, ២២២៣, ២២២៧<br>- ២២២៨, ២២២៩, ៣៣៣៦, ៣៣៣៧, ៣៣៣៨<br>- ៣៣៣៩, ៤៤៤៦, ៤៤៤៧, ៤៤៤៨, ៤៤៤៩<br>- ៦៦៦៧, ៦៦៦៨, ៦៦៦៩, ៧៧៧៨, ៧៧៧៩<br>- ៨៨៨៩, ៩៩៩៨ | ២ ០០០ ០០០ | ១ ០០០ ០០០ | ៥០០ ០០០ | ១ ០០០ ០០០ | ៥០០ ០០០ | ២៥០ ០០០ |

| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់សេរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃសេរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្ទេរក្នុងមួយសេរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| | - ០០០២, ០០០៣, ០០០៥, ០០០៦, ០០០៨ | ១ ០០០ ០០០ | ៥០០ ០០០ | ២៥០ ០០០ | ១ ០០០ ០០០ | ៥០០ ០០០ | ២៥០ ០០០ |
| | - ១១១៣, ១១១៥, ២២២១, ២២២៥, ២២២៦ | | | | | | |
| | - ៣៣៣១, ៣៣៣២, ៣៣៣៥, ៥៥៥១, ៥៥៥២ | | | | | | |
| | - ៥៥៥៣, ៦៦៦១, ៦៦៦២, ៦៦៦៣, ៦៦៦៥ | | | | | | |
| | - ៧៧៧១, ៧៧៧២, ៧៧៧៣, ៧៧៧៥, ៧៧៧៦ | | | | | | |
| | - ៨៨៨១, ៨៨៨២, ៨៨៨៣, ៨៨៨៥, ៨៨៨៦ | | | | | | |
| | - ៨៨៨៧, ៩៩៩១, ៩៩៩២, ៩៩៩៣, ៩៩៩៥ | | | | | | |
| | - ៩៩៩៦, ៩៩៩៧ | | | | | | |
| | - ០០០៤, ១១១០, ១១១៤, ២២២០, ២២២៤ | ៤០០ ០០០ | ២០០ ០០០ | ១០០ ០០០ | ៦០០ ០០០ | ៣០០ ០០០ | ១៥០ ០០០ |
| | - ៣៣៣០, ៣៣៣៤, ៤៤៤០, ៤៤៤១, ៤៤៤២ | | | | | | |
| | - ៤៤៤៣, ៤៤៤៥, ៤៤៤៦, ៤៤៤៧, ៤៤៤៨ | | | | | | |
| | - ៤៤៤៩, ៥៥៥០, ៥៥៥៤, ៦៦៦០, ៦៦៦៤ | | | | | | |
| | - ៧៧៧០, ៧៧៧៤, ៨៨៨០, ៨៨៨៤, ៩៩៩០ | | | | | | |
| | - ៩៩៩៤ | | | | | | |



| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់សេរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃសេរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្ទេរក្នុងមួយសេរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| ៨ | លេខនៅខ្ទង់ខាងដើម និងលេខនៅខ្ទង់ខាងចុង ជាលេខដូចគ្នា និងលេខទាំងពីរខ្ទង់នៅកណ្ដាល ជាលេខគូ | | | | | | |
| | - ១២២១, ១៣៣១, ១៥៥១, ១៦៦១, ១៧៧១ | ២ ០០០ ០០០ | ១ ០០០ ០០០ | ៥០០ ០០០ | ១ ០០០ ០០០ | ៥០០ ០០០ | ២៥០ ០០០ |
| | - ១៨៨១, ១៩៩១, ២១១២, ២៣៣២, ២៥៥២ | | | | | | |
| | - ២៦៦២, ២៧៧២, ២៨៨២, ២៩៩២, ៣១១៣ | | | | | | |
| | - ៣២២៣, ៣៥៥៣, ៣៦៦៣, ៣៧៧៣, ៣៨៨៣ | | | | | | |
| | - ៣៩៩៣, ៥១១៥, ៥២២៥, ៥៣៣៥, ៥៦៦៥ | | | | | | |
| | - ៥៧៧៥, ៥៨៨៥, ៥៩៩៥, ៦១១៦, ៦២២៦ | | | | | | |
| | - ៦៣៣៦, ៦៥៥៦, ៦៧៧៦, ៦៨៨៦, ៦៩៩៦ | | | | | | |
| | - ៧១១៧, ៧២២៧, ៧៣៣៧, ៧៥៥៧, ៧៦៦៧ | | | | | | |
| | - ៧៨៨៧, ៧៩៩៧, ៨១១៨, ៨២២៨, ៨៣៣៨ | | | | | | |
| | - ៨៥៥៨, ៨៦៦៨, ៨៧៧៨, ៨៩៩៨, ៩១១៩ | | | | | | |
| | - ៩២២៩, ៩៣៣៩, ៩៥៥៩, ៩៦៦៩, ៩៧៧៩ | | | | | | |
| | - ៩៨៨៩ | | | | | | |

| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់ស៊េរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃស៊េរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្ទេរក្នុងមួយស៊េរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| | - ០១១០, ០២២០, ០៣៣០, ០៤៤០, ០៥៥០ | ៤០០ ០០០ | ២០០ ០០០ | ១០០ ០០០ | ៦០០ ០០០ | ៣០០ ០០០ | ១៥០ ០០០ |
| | - ០៦៦០, ០៧៧០, ០៨៨០, ០៩៩០, ១០០១ | | | | | | |
| | - ១៩៩១, ២០០២, ២៩៩២, ៣០០៣, ៣៩៩៣ | | | | | | |
| | - ៤០០៤, ៤១១៤, ៤២២៤, ៤៣៣៤, ៤៥៥៤ | | | | | | |
| | - ៤៦៦៤, ៤៧៧៤, ៤៨៨៤, ៤៩៩៤, ៥០០៥ | | | | | | |
| | - ៥៩៩៥, ៦០០៦, ៦៩៩៦, ៧០០៧, ៧៩៩៧ | | | | | | |
| | - ៨០០៨, ៨៩៩៨, ៩០០៩, ៩៩៩៩ | | | | | | |
| ៩ | លេខពីរខ្ទង់ខាងចុងស្មើនឹងលេខពីរខ្ទង់ខាងដើមបូក ១ | | | | | | |
| | - ១២១៣, ១៥១៦, ១៦១៧, ១៧១៨, ១៨១៩ | ៦០០ ០០០ | ៣០០ ០០០ | ១៥០ ០០០ | ៨០០ ០០០ | ៤០០ ០០០ | ២០០ ០០០ |
| | - ២១២២, ២៥២៦, ២៦២៧, ២៧២៨, ២៨២៩ | | | | | | |
| | - ៣១៣២, ៣២៣៣, ៣៥៣៦, ៣៦៣៧, ៣៧៣៨ | | | | | | |
| | - ៣៨៣៩, ៥១៥២, ៥២៥៣, ៥៦៥៧, ៥៧៥៨ | | | | | | |
| | - ៥៨៥៩, ៦១៦២, ៦២៦៣, ៦៥៦៦, ៦៧៦៨ | | | | | | |
| | - ៦៨៦៩, ៧១៧២, ៧២៧៣, ៧៥៧៦, ៧៦៧៧ | | | | | | |
| | - ៧៨៧៩, ៨១៨២, ៨២៨៣, ៨៥៨៦, ៨៦៨៧ | | | | | | |
| | - ៨៧៨៨, ៩១៩២, ៩២៩៣, ៩៥៩៦, ៩៦៩៧ | | | | | | |
| | - ៩៧៩៨, ៩៨៩៩ | | | | | | |



| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់ស៊េរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃស៊េរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្ទេរក្នុងមួយស៊េរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| | - ០១០២, ០២០៣, ០៣០៤, ០៤០៥, ០៥០៦ | ១២០ ០០០ | ៦០ ០០០ | ៣០ ០០០ | ៤០០ ០០០ | ២០០ ០០០ | ១០០ ០០០ |
| | - ០៦០៧, ០៧០៨, ០៨០៩, ១០១១, ១៣១៤ | | | | | | |
| | - ១៤១៥, ២០២១, ២៣២៤, ២៤២៥, ៣០៣១ | | | | | | |
| | - ៣៤៣៥, ៤០៤១, ៤១៤២, ៤២៤៣, ៤៣៤៤ | | | | | | |
| | - ៤៥៤៦, ៤៦៤៧, ៤៧៤៨, ៤៨៤៩, ៥០៥១ | | | | | | |
| | - ៥៣៥៤, ៥៤៥៥, ៦០៦១, ៦៣៦៤, ៦៤៦៥ | | | | | | |
| | - ៧០៧១, ៧៣៧៤, ៧៤៧៥, ៨០៨១, ៨៣៨៤ | | | | | | |
| | - ៨៤៨៥, ៩០៩១, ៩៣៩៤, ៩៤៩៥ | | | | | | |
| ១០ | លេខពីរខ្ទង់ខាងចុង ជាលេខគូ | | | | | | |
| | - ..១១, ..២២, ..៣៣, ..៤៤, ..៦៦, | ៤០០ ០០០ | ២០០ ០០០ | ១០០ ០០០ | ៦០០ ០០០ | ៣០០ ០០០ | ១៥០ ០០០ |
| | - ..៧៧, ..៨៨, ..៩៩ | | | | | | |
| ១១ | លទ្ធផលខ្ទង់ភាយនៃផលបូកលេខទាំងបួនខ្ទង់ (ក្រៅពីលេខពិសេសដែលបានកំណត់ខាងលើ) ៖ | | | | | | |
| | - ជាលេខ ៧ ឬ ជាលេខ ៨ ឬ ជាលេខ ៩ | ១០០ ០០០ | ៥០ ០០០ | ២៥ ០០០ | ៤០០ ០០០ | ២០០ ០០០ | ១០០ ០០០ |
| | - ជាលេខ ៦ | ៨០ ០០០ | ៤០ ០០០ | ២០ ០០០ | ៤០០ ០០០ | ២០០ ០០០ | ១០០ ០០០ |
| II | **លេខធម្មតា** | មិនគិតថ្លៃ | | | ៤០០ ០០០ | ២០០ ០០០ | ១០០ ០០០ |

តារាងឧបសម្ព័ន្ធភ្ជាប់នៅនឹងប្រកាសលេខ ៨៦៣...... សហវ.ប្រក ចុះថ្ងៃទី...១៩...... ខែកក្កដា ឆ្នាំ២០១៦

ស្តីពីការលក់លេខចុះបញ្ជីរថយន្តទេសចរ និងរថយន្តធុនស្រាល

រូបិយវត្ថុ : រៀល

| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់ស៊េរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃស៊េរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្លោះក្នុងមួយស៊េរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| I | លេខពិសេស | | | | | | |
| ១ | លេខទាំងបួនខ្ទង់ ជាលេខដូចគ្នា | | | | | | |
| | - ៧៧៧៧, ៨៨៨៨, ៩៩៩៩ | ២០ ០០០ ០០០ | ១០ ០០០ ០០០ | ៥ ០០០ ០០០ | ២ ៥០០ ០០០ | ១ ២៥០ ០០០ | ៦២៥ ០០០ |
| | - ១១១១, ២២២២, ៣៣៣៣, ៥៥៥៥, ៦៦៦៦ | ១៦ ០០០ ០០០ | ៨ ០០០ ០០០ | ៤ ០០០ ០០០ | ២ ០០០ ០០០ | ១ ០០០ ០០០ | ៥០០ ០០០ |
| | - ៤៤៤៤ | ៤ ០០០ ០០០ | ២ ០០០ ០០០ | ១ ០០០ ០០០ | ១ ២០០ ០០០ | ៦០០ ០០០ | ៣០០ ០០០ |
| ២ | មានលេខ ១៦៨ ស្ថិតនៅបីខ្ទង់ខាងចុង | | | | | | |
| | - ០១៦៨, ១១៦៨, ២១៦៨, ៣១៦៨, ៤១៦៨<br>- ៦១៦៨, ៧១៦៨, ៨១៦៨, ៩១៦៨ | ១៦ ០០០ ០០០ | ៨ ០០០ ០០០ | ៤ ០០០ ០០០ | [illegible] | ១ ០០០ ០០០ | ៥០០ ០០០ |
| | - ៥១៦៨ | ៣ ២០០ ០០០ | ១ ៦០០ ០០០ | ៨០០ ០០០ | ១ ០០០ ០០០ | [illegible] | ២៥០ ០០០ |
| ៣ | លេខទាំងបួនខ្ទង់ ជាលេខរៀងគ្នាតាមលំដាប់ឡើង | | | | | | |
| | - ៥៦៧៨, ៦៧៨៩ | ១០ ០០០ ០០០ | ៥ ០០០ ០០០ | ២ ៥០០ ០០០ | ១ ៥០០ ០០០ | ៧៥០ ០០០ | ៣៧៥ ០០០ |
| | - ០១២៣, ១២៣៤, ២៣៤៥, ៣៤៥៦, ៤៥៦៧ | ៦ ០០០ ០០០ | ៣ ០០០ ០០០ | ១ ៥០០ ០០០ | ១ ៥០០ ០០០ | ៧៥០ ០០០ | ៣៧៥ ០០០ |



| ល.រ | បរិយាយប្រភេទលេខចុះបញ្ជីរថយន្ត | តម្លៃលក់ក្នុងមួយលេខ សម្រាប់ស៊េរីលេខចុះបញ្ជីបច្ចុប្បន្នភាព | | | តម្លៃត្រូវបង់បន្ថែមលើតម្លៃនៃស៊េរីលេខចុះបញ្ជីបច្ចុប្បន្នភាព ដោយគិតក្នុងមួយលេខសម្រាប់ការផ្លោះក្នុងមួយស៊េរី | | |
|---|---|---|---|---|---|---|---|
| | | តំបន់ ១ | តំបន់ ២ | តំបន់ ៣ | តំបន់ ១ | តំបន់ ២ | តំបន់ ៣ |
| ៤ | លេខពីរខ្ទង់ខាងដើម និងលេខពីរខ្ទង់ខាងចុង ជាលេខគូ | | | | | | |
| | - ១១២២, ១១៣៣, ១១៥៥, ១១៦៦, ១១៧៧<br>- ១១៨៨, ១១៩៩, ២២១១, ២២៣៣, ២២៥៥<br>- ២២៦៦, ២២៧៧, ២២៨៨, ២២៩៩, ៣៣១១<br>- ៣៣២២, ៣៣៥៥, ៣៣៦៦, ៣៣៧៧, ៣៣៨៨<br>- ៣៣៩៩, ៥៥១១, ៥៥២២, ៥៥៣៣, ៥៥៦៦<br>- ៥៥៧៧, ៥៥៨៨, ៥៥៩៩, ៦៦១១, ៦៦២២<br>- ៦៦៣៣, ៦៦៥៥, ៦៦៧៧, ៦៦៨៨, ៦៦៩៩<br>- ៧៧១១, ៧៧២២, ៧៧៣៣, ៧៧៥៥, ៧៧៦៦<br>- ៧៧៨៨, ៧៧៩៩, ៨៨១១, ៨៨២២, ៨៨៣៣<br>- ៨៨៥៥, ៨៨៦៦, ៨៨៧៧, ៨៨៩៩, ៩៩១១<br>- ៩៩២២, ៩៩៣៣, ៩៩៥៥, ៩៩៦៦, ៩៩៧៧<br>- ៩៩៨៨ | ៤ ០០០ ០០០ | ២ ០០០ ០០០ | ១ ០០០ ០០០ | ១ ២០០ ០០០ | [illegible] | ៣០០ ០០០ |